## រឿងទី៣៖ កាអ៊ីន និងអេបិល

**ខគម្ពីរ៖ ម៉ាថាយ១៩:១៤**

ប្រសិនបើអ្នកប្រព្រឹត្តល្អ អ្នកនឹងបានរីករាយឡើងវិញជាមិនខាន ផ្ទុយទៅវិញ បើអ្នកមិនប្រព្រឹត្តល្អទេ បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកឲ្យធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ»។

អដាំ និងអេវ៉ាដែលព្រះជាម្ចាស់បានបង្កើតមកនោះ ពួកគេបានបង្កើតកូនប្រុសពីរនាក់។
កូនច្បងឈ្មោះ«កាអ៊ីន» កូនប្អូនឈ្មោះ«អេបិល»។ កូនទាំងពីរបានធំធាត់ពីមួយថ្ងៃទៅមួយថ្ងៃ។
កាអ៊ីនជាបង ប្រកបរបរធ្វើស្រែចម្ការ។ ចំណែកអេបិលជាប្អូនវិញ ប្រកបរបរជាគង្វាលចៀម។
លុះដល់ពេលប្រមូលផល អេបិលជាប្អូនបាននាំយកកូនសត្វដែលកើតមុនគេបង្អស់ក្នុងហ្វូងសត្វរបស់គាត់ ព្រមទាំងខ្លាញ់របស់វាមកថ្វាយជាយញ្ញបូជាដល់ព្រះជាម្ចាស់។
កាអ៊ីនជាបង ក៏បានយកភោគផលពីស្រែចម្ការរបស់គាត់មកថ្វាយជាយញ្ញបូជាដល់ព្រះជាម្ចាស់ដែរ។
ប៉ុន្តែព្រះជាម្ចាស់ទទួលយកតែតង្វាយរបស់អេបិលទេ តង្វាយរបស់កាអ៊ីនទ្រង់ទុកចោលនៅទីនោះដដែល។
កាអ៊ីនមានការខឹងក្រោធជាខ្លាំង រហូតសម្រេចថានឹងស្អប់អេបិលជាប្អូនថែមទៀត។
ការអាក់អន់ចិត្តជាមួយព្រះជាម្ចាស់ និងចិត្តច្រណែនអេបិលជាប្អូនបានគ្រប់ដណ្ដប់ពេញក្នុងចិត្តរបស់កាអ៊ីន។
មានថ្ងៃមួយ មិនដឹងថាមានរឿងអ្វីទេ គ្មានអ្នកណាឃើញអេបិលសោះ។ ព្រះជាម្ចាស់បានសួរទៅកាអ៊ីនថា៖ «កាអ៊ីនអើយ តើអេបិលប្អូនឯងនៅឯណា?
កាអ៊ីនបានតបទៅព្រះជាម្ចាស់ថា៖ «ព្រះអង្គអើយ! តើធ្វើដូចម្ដេចដឹងថាប្អូនទូលបង្គំនៅឯណាទៅ? តើទូលបង្គំជាអ្នកឃ្វាលប្អូនទូលបង្គំឬ?»
ព្រះជាម្ចាស់ទ្រង់ជ្រាបគ្រប់អ្វីទាំងអស់ ពីរឿងដែលកាអ៊ីនបានសម្លាប់អេបិលជាប្អូននោះ។
ព្រះជាម្ចាស់ទ្រង់ជ្រាបគ្រប់អ្វីទាំងអស់ ហើយទ្រង់ធ្វើជាសួរទៅកាអ៊ីន ប៉ុន្តែកាអ៊ីនបានកុហកព្រះជាម្ចាស់។ ព្រះជាម្ចាស់បានដាក់ទោសកាអ៊ីន។
ទោះបីជាកាអ៊ីនជាមនុស្សមានបាបក៏ពិតមែន ប៉ុន្តែព្រះជាម្ចាស់នៅតែមានព្រះហឫទ័យអាណិតដល់កាអ៊ីន
ទ្រង់បានសន្យាជាមួយកាអ៊ីនថានឹងមិនឱ្យអ្នកណាម្នាក់សម្លាប់គាត់ឡើយ។



**សកម្មភាពទី១** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



● សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ៤:៧)

បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកឲ្យធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ

**សកម្មភាពទី២** កាត់រូបភាពតង្វាយ ដាក់ឱ្យត្រូវតាមកន្លែងនីមួយៗ។






